F19

F19

# បច្ចេកទេសបំប៉នកូនត្រីពូជ
# ទីឡាព្យ៉ា ឆ្ពិន កាបសាមញ្ញ និង កាបស



## រូបមន្តសំខាន់ៗដែលអ្នកគួរចងចាំ ដើម្បីងាយយល់ការអធិប្បាយក្នុងសៀវភៅនេះ

**ផ្ទៃក្រឡាស្រែជាម៉ែត្រការ៉េ = ប្រវែងបណ្ដោយស្រែជាម៉ែត្រ x ប្រវែងទទឹងស្រែជាម៉ែត្រ**

ឧទាហរណ៍ : ស្រែមានប្រវែងបណ្ដោយ១៥ម និង ទទឹង១០ម ។ ផ្ទៃក្រឡាស្រែ = ១៥ម x ១០ម = ១៥០ម$^{២}$

**បរិមាណកំបោរប្រើប្រាស់ក្នុងស្រែ = ផ្ទៃក្រឡាស្រែជាម៉ែត្រការ៉េ x $\frac{\text{បរិមាណកំបោរប្រើក្នុង ១០០ម}^{២}}{១០០}$**

ឧទាហរណ៍ : ស្រែមានផ្ទៃក្រឡា១៥០ម$^{២}$ ចង់ប្រើកំបោរ ១០គក្រ ក្នុង១០០ម$^{២}$ ។ បរិមាណកំបោរប្រើប្រាស់ក្នុងស្រែ = ១៥០ x $\frac{១០}{១០០}$ = ១៥គក្រ

**ចំនួនកូនត្រីដាក់ចិញ្ចឹមក្នុងស្រែ = ផ្ទៃក្រឡាស្រែជាម៉ែត្រការ៉េ x ចំនួនកូនត្រីដាក់ចិញ្ចឹមក្នុង ១ម$^{២}$**

ឧទាហរណ៍ : ស្រែមានផ្ទៃក្រឡា១៥០ម$^{២}$ ចង់ដាក់ត្រីចិញ្ចឹម ៣ក្បាល ក្នុង១ម$^{២}$ ។ ចំនួនកូនត្រីដាក់ចិញ្ចឹម = ១៥០ x ៣ = ៤៥០ក្បាល

**បរិមាណជីអ៊ុយរ៉េប្រើប្រាស់ក្នុងស្រែ = ផ្ទៃក្រឡាស្រែជាម៉ែត្រការ៉េ x $\frac{\text{បរិមាណជីអ៊ុយរ៉េប្រើក្នុង ១០០ម}^{២}}{១០០}$**

ឧទាហរណ៍ : ស្រែមានផ្ទៃក្រឡា១៥០ម$^{២}$ ចង់ប្រើជីអ៊ុយរ៉េ ៤ខាំ ក្នុង ១០០ម$^{២}$ ។ បរិមាណជីអ៊ុយរ៉េប្រើប្រាស់ក្នុងស្រែ = ១៥០ x $\frac{៤}{១០០}$ = ៦ខាំ

# មាតិកា

## បច្ចេកទេសបំប៉នកូនត្រី


| | ទំព័រ |
|---|---|
| ១- ការបំប៉នកូនត្រីក្នុងស្រះ | ៣ |
| ក. ការថែបំប៉នកូនត្រីមេស្អៀ និងកូនត្រីពួជ | ៣ |
| ក.១- ស្រះ និង ការរៀបចំស្រះ | ៣ |
| ក.២- ការលែងកូនត្រី ចូលស្រះបំប៉ន | ៥ |
| ក.៣-ការប្រើប្រាស់ចំណីបន្ថែម ក្រោយពេលលែងកូនត្រី | ៧ |
| ក.៤- ការប្រើប្រាស់ជី ក្រោយពេលលែងកូនត្រី | ៨ |
| ខ. ការគ្រប់គ្រង | ៩ |
| ២- ការបំប៉នកូនត្រីក្នុងហាប៉ា | ១០ |
| ក. បច្ចេកទេសដេរហាប៉ា និង ការរៀបចំហាប៉ាក្នុងស្រះ | ១០ |
| ខ. ការថែបំប៉នកូនត្រីមេស្អៀ និង កូនត្រីពួជ | ១១ |
| ខ.១- ការលែងកូនត្រីចូលហាប៉ាបំប៉ន | ១១ |
| ខ.២- ការប្រើប្រាស់ចំណីបន្ថែម ក្រោយពេលលែងកូនត្រី | ១២ |
| ខ.៣- ការប្រើជី ក្រោយពេលលែងកូនត្រី | ១២ |
| គ. ការគ្រប់គ្រង | ១៣ |


## បច្ចេកទេសដឹកជញ្ជូនកូនត្រី


| | ទំព័រ |
|---|---|
| ១- ការរៀបចំកូនត្រីតូច មុនពេលវេចខ្ចប់ដឹកជញ្ជូនសំរាប់លក់ | ១៤ |
| ២- ការវេចខ្ចប់កូនត្រីតូច | ១៥ |
| ក. ការដឹកជញ្ជូន ដោយប្រើថង់ | ១៥ |
| ខ. ការដឹកជញ្ជូន ដោយប្រើធុង ផ្លាំង | ១៦ |

# សេចក្តីផ្តើម

ការចិញ្ចឹមត្រីជាផ្នែកមួយយ៉ាងសំខាន់ ក្នុងវិស័យកសិកម្ម ដែលផ្តល់ប្រយោជន៍យ៉ាងច្រើន ដល់ការបំរើជីវភាពផ្នែកម្ហូបអាហារ របស់ប្រជារាស្ត្រ ពិសេស ប្រជាកសិករក្រីក្រ ដែលរស់នៅឆ្ងាយពី ដែនទេសាទ ដូចជា ÷ ឡូត៍នេសាទ -ទន្លេ -បឹង - ព្រែក រឺ តំបន់ទឹកធម្មជាតិនានា ។ ដើម្បីបំពេញគោលបំនងដ៏សំខាន់ និង ចាំបាច់នេះ នាយកដ្ឋានជលផលបាន និងកំពុងយកចិត្តទុកដាក់ ជំរុញផ្នែកចិញ្ចឹមត្រីនេះឱ្យមានការអភិវឌ្ឍន៍ ដល់តំបន់ជាច្រើនដែលខ្សត់ត្រី នៅក្នុងបណ្តាខេត្តមួយចំនួន នៃព្រះរាជាណាចក្រកម្ពុជា ដោយបញ្ជូនអ្នកជំនាញបច្ចេកទេសចិញ្ចឹមត្រី ចុះជួយបង្ហាត់បង្រៀនកសិករ ឱ្យចេះរបៀបចិញ្ចឹមត្រី និង រៀបចំការគ្រប់គ្រងអភិវឌ្ឍន៍ការចិញ្ចឹមត្រីឱ្យបានល្អ ដើម្បីជួយដោះស្រាយជីវភាពផ្នែកម្ហូបអាហាររបស់គាត់ ។

ដោយយល់ឃើញថា តំរូវការចង់ទទួលចំណេះដឹង បច្ចេកទេសចិញ្ចឹមត្រី របស់កសិករជាច្រើន ដែលបច្ចុប្បន្ន កំពុងតែជួបប្រទះ ការខ្វះខាតម្ហូប-អាហារត្រីប្រចាំគ្រួសារ ហើយដែលអ្នកជំនាញនាយកដ្ឋានជលផល មិនអាចចុះបង្ហាត់កសិករទាំងអស់ក្នុងព្រះរាជាណាចក្រកម្ពុជាឱ្យចេះចិញ្ចឹមត្រីបាននាយកដ្ឋានជលផលបានរៀបចំចងក្រងសៀវភៅផ្សព្វផ្សាយស្តីពី " បច្ចេកទេសចិញ្ចឹមត្រីជាលក្ខណៈគ្រួសារ " ហើយបានចែកចាយជូនដល់ប្រជាកសិករ ក្នុងបណ្តាខេត្តជាច្រើន តាមរយៈអ្នកជំនាញកសិកម្ម ដែលកំពុងជួយផ្សព្វផ្សាយបច្ចេកទេសចិញ្ចឹមត្រី ។ ម៉្យាងទៀតដោយមានអង្គការក្រៅរដ្ឋាភិបាលជាច្រើនបានជួយជំរុញការងារ ចិញ្ចឹមត្រីនេះ ដល់កសិករនៅតាមជនបទផងដែរនោះ បានធ្វើឱ្យកសិករមួយភាគធំ ខ្វះកូនត្រីពូជសំរាប់ចិញ្ចឹម ។ ហេតុនេះនាយកដ្ឋានជលផល ផលិតសៀវភៅផ្សព្វផ្សាយស្តីពី " បច្ចេកទេសបំប៉នកូនត្រីពូជ ជាលក្ខណៈគ្រួសារ " ហើយនឹង មានគំរោងរៀបចំផលិតសៀវភៅបច្ចេកទេសមួយទៀត ស្តីពី " បច្ចេកទេសបង្កាត់ និង ភ្ញាស់ត្រីជាលក្ខណៈគ្រួសារ " សំដៅជួយបង្ហាត់បង្រៀនកសិករ ដែលមានបទពិសោធន៍ចិញ្ចឹមត្រីជាច្រើនឆ្នាំ ឱ្យចេះបច្ចេកទេសបំប៉ន និង ផលិតកូនត្រីពូជ ដើម្បីជួយដោះស្រាយបញ្ហាកង្វះខាតកូនត្រីពូជសំរាប់ចិញ្ចឹម ។

**ដូចនេះដើម្បីឱ្យសៀវភៅ "បច្ចេកទេសបំប៉នកូនត្រី "បំរើផលប្រយោជន៍ល្អដល់អ្នកចិញ្ចឹមត្រី ពិសេសកសិករដែលមានបទពិសោធន៍ចិញ្ចឹមត្រីហើយ នាយកដ្ឋានជលផលសំនូមពរ ឱ្យគ្រួសារកសិករចិញ្ចឹមត្រីទាំងអស់ បង្កើតជា-ក្រុមពិភាក្សាគ្នា អានសៀវភៅនេះដោយយកចិត្តទុកដាក់ នោះសៀវភៅនេះនឹងណែនាំ និងបង្ហាត់បង្រៀនអ្នកឱ្យចេះពីបច្ចេកទេសបំប៉នកូនត្រី បានពិតប្រាកដ ។**

# បច្ចេកទេសបំប៉នកូនត្រី

## ១- ការបំប៉នកូនត្រីក្នុងស្រះ

ការថែបំប៉នកូនត្រីក្នុងស្រះ គេបំប៉នវាជាពីរតំណាក់កាលផ្សេងៗគ្នាគឺ : ដំណាក់កាល បំប៉នកូនត្រីម៉្សៅ និង ដំណាក់កាលបំប៉នកូនត្រីពូជ ។

## ក- ការថែបំប៉នកូនត្រីម្សៅ និងកូនត្រីពូជ

### ក.១- ស្រះ និង ការរៀបចំស្រះ

ស្រះសមស្របអាចបំប៉នកូនត្រីបានល្អ មានលក្ខណះដូចតទៅ :

- ស្រះបំប៉ន គួរមានទំហំពី ៥០ម៉ែត្រការេ ទៅ ២០០ម៉ែត្រការេ ឬ មានបណ្តោយពី ១០ម៉ែត្រ ទៅ២០ម៉ែត្រ ទទឹងពី ៥ម៉ែត្រ ទៅ ១០ម៉ែត្រ និង ជំរៅ ពី កន្លះម៉ែត្រ ទៅ ១ ម៉ែត្រ ។




- ភក់បាតស្រះមិនត្រូវអោយលើសកំរាស់ពី ១០ ទៅ ២០សង់ទីម៉ែត្រ រឺ ១ ទៅ ២តឹក ។
- ចំពោះស្រះមានទឹកស្រាប់ ហើយកសិករពុំមានលទ្ធភាព បូមទឹកស្រះពង្រីង ដើម្បីចាប់ត្រីស្រែចេញ នោះកសិករត្រូវ ÷

☞ ចាប់ត្រីស្រែចេញ ដោយប្រើបង្គៃ អួសអួន ។ល។ និង ការពារកុំឱ្យត្រីកាចពី ខាងក្រៅលោតចូល ហើយត្រូវប្រើកំបោរសពី ៣ ទៅ៤គីឡូក្រាម ក្នុងស្រះ១០០ម៉ែត្រការេ ។ ប្រសិនជាអ្នកចង់សំលាប់ត្រីស្រែ អ្នកត្រូវប្រើបរិមាណកំបោរសច្រើនជាងនេះ ។ អ្នកត្រូវលាយកំបោរស ជាមួយទឹកដាក់ក្នុងធុងដែក រួចកូរឱ្យបានសព្វ មុននឹងយកទៅបាចលើផ្ទៃស្រះ ។

☞ ក្រោយពីប្រើកំបោរសពី ៤ ទៅ ៧ថ្ងៃ កសិករត្រូវប្រើជី អុយរ៉េ ៣ខាំ លាយជាមួយជី ដេអាប៉េ ១ខាំ ក្នុងស្រះ ១០០ម៉ែត្រការេ ឬ អ្នកអាចប្រើជំនួសដោយ ជីលាមកសត្វពី ៣ ទៅ ៥បង្គី និង ជីទន្រ្ទាងខែត្រ ពី២ ទៅ ៤បាច់ ( មួយបាច់ ទំងន់ ៥គក្រ) ក្នុងស្រះ ១០០ម៉ែត្រការេ ដូចគ្នា ។

☞ ចំពោះជី អុយរ៉េ និង ដេអាប៉េ អ្នកត្រូវលាយទឹកឱ្យរលាយអស់សិន រួចទើបបាចឱ្យសព្វពេញផ្ទៃស្រះ ។

☞ រួចរង់ចាំពេលពី ៤ ទៅ ៧ថ្ងៃ រហូតដល់ទឹកមានពណ៌បៃតង ទើបលែងកូនត្រីបាន ។ តែបើទឹកស្រះ មិនទាន់មានពណ៌ បៃតង អ្នកត្រូវប្រើបរិមាណជីបន្ថែម ដូចខាងលើ ។

☞ បើនៅជុំវិញស្រះបំប៉នរបស់អ្នក មានវាលស្រែ និងមានទឹកព័ទ្ធជុំវិញ អ្នកត្រូវយកស្បែនីឡុងក្រលាល្អិតមកបាំងព័ទ្ធជុំវិញស្រះ ដើម្បីការពារកុំឱ្យត្រីស្រែលោតចូលស្រះស៊ីកូនត្រី ។




● ប្រសិនបើកសិករផ្សេងទៀតមានលទ្ធភាពបូមទឹកស្រះពង្រីង កសិករត្រូវ

☞ ប្រើកំបោរសពី ៥ ទៅ ៨គីឡូក្រាម ក្នុងស្រះ ១០០ម៉ែត្រការេ ហើយ បាចរាយអោយស្មើពេញផ្ទៃបាត និង ជញ្ជាំងស្រះ ។

ម៉្យាងកំបោរស



ដូចជា ត្រីផ្ទក់ , ត្រីអណ្ដែង ,ត្រីក្រាញ់ , ត្រីចង្វា , ក្ដាម ,អន្ទង់ ។ល។ និង សត្វល្អិតចង្រៃ ផ្សេងៗទៀត ទើបបញ្ចូលទឹកពី ០,៤ ម៉ែត្រ ទៅ ០,៦ម៉ែត្រ ( រឺ ពី ៤តឹក ទៅ ៦តឹក ) ចំពោះស្រះបំប៉ន ដែលមានជំរៅតែពីកន្លះម៉ែត្រ ទៅ ១ ម៉ែត្រ ប៉ុណ្ណោះ ។

☞ ក្រោយពី បញ្ចូលទឹកហើយ១ថ្ងៃ កសិករត្រូវប្រើជីលាមកសត្វ ពី ៣ ទៅ ៥ បង្គី និង ជីទន្រ្ទាងខែត្រពី ២ ទៅ៤បាច់ ( មួយបាច់ ទំងន់ ៥ គក្រ) ក្នុងស្រះ១០០ ម៉ែត្រការេ ឬ អ្នកអាចប្រើជំនួសដោយ ជីអុយរ៉េ ៣ខាំ លាយជាមួយ ជីដេអាប៉េ ១ខាំ ក្នុងស្រះ១០០ម៉ែត្រការេ ដូចគ្នា ។

☞ ចំពោះជី អុយរ៉េ និង ដេអាប៉េ អ្នកត្រូវលាយទឹកឱ្យរលាយអស់សិន រួច ទើបបាចឱ្យសព្វពេញផ្ទៃស្រះ ។

☞ រយៈពេលពី ៤ទៅ ៧ថ្ងៃក្រោយមក ទើបទឹកស្រះមានពណ៌បៃតងល្អ ហើយកសិករអាចលែងកូនត្រីបាន ។ តែបើទឹកស្រះមិនទាន់មានពណ៌បៃតង អ្នកត្រូវប្រើបរិមាណជីបន្ថែម ដូចខាងលើ ។

## ក.២- ការលែងកូនត្រី ចូលស្រះបំប៉ន

- លក្ខខ័ណ្ឌចាំបាច់ មុននឹងលែងកូនត្រីចូលស្រះបំប៉ន កសិករត្រូវធ្វើទឹកស្រះឱ្យមានពណ៌បៃតងល្អជាមុនសិន ទើបអាច លែង កូនត្រីបាន ។
- ត្រូវលែងកូនត្រីនៅពេលព្រឹកព្រលឹម រឺពេលមេឃត្រជាក់ តែចៀសវាងលែងកូនត្រីនៅពេលល្ងាច មេឃជិតភ្លៀង រឺពេលកំពុងភ្លៀង រឺពេលភ្លៀងរួច ចំពោះកូនត្រីដែលដឹកជញ្ជូនពីទីឆ្ងាយ មុនពេលលែងកូនត្រីចូលក្នុងស្រះត្រូវត្រាំធុង ឬ ថង់កូនត្រី ក្នុងស្រះ រយៈពេលពី ៥ ទៅ១០ នាទី ជាមុនសិន រួចបាចទឹកបន្តិចម្តងៗ ចូលក្នុងធុង រឺ ថង់កូនត្រីនោះ ដើម្បីឱ្យសីតុណ្ហភាពទឹកក្នុងធុង រឺថង់ មានសីតុណ្ហភាព ដូចគ្នានឹង ទឹកស្រះ ។
- ត្រូវផ្អៀងមាត់ធុង ឬថង់ អោយកូនត្រីចេញយឺតៗ ។
- ជាទូទៅកូនត្រីម៉េ្យា គេបំប៉នរយៈពេល ២អាទិត្យ រឺចាប់ពីទំហំ ១ ស.ម រហូតដល់ មានទំហំ ២ ស.ម ទៅ ៣ ស.ម ។
- ចំពោះកូនត្រីពូជ អ្នកត្រូវបំប៉នចាប់ពីទំហំ ២ រឺ ៣ស.ម រហូតដល់កូនត្រីមានទំហំពី ៤ ទៅ៦ស.ម រឺត្រូវបំប៉នរយៈពេល ៤អាទិត្យបន្តទៀត បន្ទាប់ពីរយៈពេលបំប៉នកូនត្រីម៉េ្យារួច ។



- កូនត្រីម៉េ្យា កាបសាមញ្ញ អាចដាក់ជាមួយនឹងកាបស ដែលមានអាយុពី ៥ ទៅ៧ថ្ងៃ ដូចគ្នា ឬ មានទំហំ ១ ទៅ១.៥ស.ម អាចយកមកបំប៉នក្នុងស្រះ កូនត្រីម៉េ្យា ។
- កូនត្រីម៉េ្យាទីឡាព្យា ដាក់ជាមួយនឹងឆ្ពិន ដែលមាន អាយុពី ៥ ទៅ៧ថ្ងៃដូចគ្នា ឬមានទំហំ១ ទៅ១.៥ស.មអាចយកមកបំប៉នក្នុងស្រះកូនត្រីម៉េ្យា ។
- កូនត្រីពូជកាបសាមញ្ញជាមួយនឹងកាបស ដែលមានអាយុពី ១៩ទៅ ២១ ថ្ងៃដូចគ្នា ឬមានទំហំ២ ទៅ៣ស.ម អាចយកមកបំប៉នក្នុងស្រះកូនត្រីពូជបាន

● កូនត្រីពូជទីឡាព្យ៉ា ជាមួយនិងឆ្ពិន ដែលមានអាយុពី ១៩ ទៅ ២១ថ្ងៃ ដូចគ្នា ឬមានទំហំ ២ ទៅ៣ស.ម អាចយកមកបំប៉នក្នុងស្រះកូនត្រីពូជបាន




● ចំពោះកូនត្រីម្ស៉ៅ ដែលមានទំហំពី ១ ទៅ ១.៥ស.ម អាចដាក់បានចំនួនពី ២០០ ទៅ៣០០ក្បាល ក្នុង១ម៉ែត្រការេ ។

● តែចំពោះកូនត្រីពូជ ទំហំពី ២ ទៅ ៣ស.ម អ្នកអាចដាក់បានចំនួនពី ១០០ ទៅ១៥០ក្បាល ក្នុង១ម៉ែត្រការេ ។

● កូនត្រីដែលដាក់បំប៉ន ត្រូវមានទំហំប៉ុនគ្នា បើមិនដូច្នេះទេកូនត្រីធំស៊ីកូនត្រីតូច ។

● កូនត្រីទីឡាព្យ៉ា និងឆ្ពិន អ្នកអាចដាក់ បំប៉នចូលគ្នា ក្នុងស្រះតែមួយក៏បាន ឬ ដោយឡែកពីគ្នាក៏បាន អាស្រ័យកសិករមានចំនួនស្រះបំប៉នតិច រឺ ច្រើន ។

● ហើយកូនត្រីកាបសាមញ្ញ និងកាបស អ្នកអាចដាក់ បំប៉នចូលគ្នាក្នុងស្រះតែមួយក៏បាន ឬ ដោយឡែកពីគ្នាក៏បាន ។

● ដើម្បីអោយកូនត្រីលូតលាស់បានល្អ និង ងាយស្រួលក្នុងការរាប់កូនត្រី លក់កសិករគួរតែបំប៉នកូនត្រី ដាច់ដោយឡែក១ពីគ្នា តាមប្រភេទនីមួយ១



ក.៣- ការប្រើប្រាស់ចំណីបន្ថែម ក្រោយពេលលែងកូនត្រី

ដើម្បីអោយកូនត្រីឆាប់ធំ កសិករគួរយក ÷

● ត្រីចង្វា ឬ ត្រីល្អិត១ផ្សេងទៀត យកមកហាលអោយស្ងួត ហើយបុកឱ្យម៉ត់លាយជាមួយកន្ទក់ម៉ត់ ។



● នៅពេលអ្នកលាយចំណីត្រីចំនួន ១គក្រ គឺត្រូវលាយម៉្សៅត្រី ២ខាំ និងកន្ទក់ម៉ត់ ៨ខាំ ៕

● អ្នកអាចប្រើ ម៉្សៅវីតាមីន ប្រភេទ អា ដេ តែ១ខាំ អាចលាយជាមួយកន្ទក់ម៉ត់ ៩ខាំ ។




● បរិមាណចំណី និង ការផ្តល់ចំណី ចំពោះកូនត្រីម៉្សៅ ÷

ជាទូទៅកូនត្រីម៉្សៅ កសិករត្រូវបំប៉នឱ្យបានរយះពេល ២អាទិត្យ ដោយ

☞ អោយចំណីកូនត្រី ២ ទៅ ៣ដង ក្នុងមួយថ្ងៃ

☞ ការផ្តល់ចំណីគួរប្រព្រឹត្តទៅ នៅពេលព្រឹក រសៀល និង ល្ងាច ឬ ពី ៣ ទៅ៤ម៉ោងម្តង ។

☞ ចំពោះកូនត្រីម៉្សៅ ២៥០០ក្បាល អ្នកត្រូវផ្តល់ចំណី នៅអាទិត្យទី ១ ចំនួនកន្លះខាំ ឬ កន្លះកំប៉ុងទឹកដោះគោ ហើយនៅអាទិត្យទី ២ អ្នកត្រូវឱ្យពី កន្លះកំប៉ុង ទៅ ១កំប៉ុងទឹកដោះគោ ក្នុង១ថ្ងៃ ។

● បរិមាណចំណី និង ការផ្តល់ចំណី ចំពោះកូនត្រីពូជ ÷

កូនត្រីម៉្យ៉ា ក្រោយពេលបំប៉នបាន រយៈពេល ២អាទិត្យដំបូងហើយ ពេលនោះវាអាចមានទំហំធំពី២ ទៅ៣ស.ម ធ្វើឱ្យស្រះចង្អៀត ដូចនេះកសិករ

☞ ត្រូវជួសវាយកមកបំប៉ន ក្នុងស្រះបំប៉នកូនត្រីពូជផ្សេងទៀត សំរាប់ រយៈពេល ៤អាទិត្យបន្តទៀត បន្ទាប់មក

☞ គួរអោយចំណី កូនត្រីពូជ ២ដង ក្នុងមួយថ្ងៃ

☞ ការផ្តល់ចំណីគួរប្រព្រឹត្តទៅ នៅពេលព្រឹក និង ពេលល្ងាច

☞ ចំពោះកូនត្រីពូជ ២០០០ក្បាល ត្រូវផ្តល់ចំណីបន្ថែមពី កន្ទះខាំ ឬកន្ទះ កំប៉ុងទឹកដោះគោ ក្នុង១ថ្ងៃ សំរាប់រយៈពេល ២អាទិត្យដំបូង ព្រោះទំហំ កូនត្រីពូជពេលនេះ អាចស៊ី ឬង់គុងបានច្រើន ។

☞ ហើយចាប់ពី អាទិត្យទី៣ ត្រូវផ្តល់ចំណី ១កំប៉ុងទឹកដោះគោ ក្នុង១ថ្ងៃ សំរាប់រយៈពេល២អាទិត្យបន្តទៀត ។

● បរិមាណចំណីផ្តល់អោយកូនត្រី កសិករគួរពិនិត្យតាមការជាក់ស្តែង

● ចៀសវាងផ្តល់ចំណីច្រើនពេក នាំអោយខាតបង់ និងស្អុយទឹក

● ចៀសវាងផ្តល់ចំណីតិចពេក នាំអោយកូនត្រីពុំលូតលាស់បានល្អ

ក.៤- <u>ការប្រើជី ក្រោយពេលលែងកូនត្រី</u>

ក្រៅពីចំណីបន្ថែមខាងលើ ចំណីធម្មជាតិ(ឬង់គុង) មានសារៈសំខាន់ណាស់ ចំពោះការបំប៉នកូនត្រី ដូច្នេះកសិករត្រូវ÷

● កែប្រែទឹកក្នុងស្រះអោយមានពណ៌បៃតងជានិច្ច ដោយប្រើតែជី អុយរ៉េ ៣ ខាំ លាយជាមួយ ជី ដេ អា ប៉េ ១ខាំ ក្នុងស្រះ១០០ម៉ែត្រការេ ។

● ចៀសវាងការប្រើជីអុយរ៉េ និង ដេ អា ប៉េ ច្រើនជាងបរិមាណជី ដែលបានកំនត់ខាងលើ ព្រោះបើអ្នកប្រើជីច្រើនពេក នាំឱ្យកូនត្រីអាចស្លាប់បាន ។




● ជីអុយរ៉េ និង ជីដេអាប៉េ ត្រូវយកវាទៅលាយជាមួយទឹក អោយរលាយអស់សិន ទើបយកវាទៅបាចអោយសព្វលើផ្ទៃស្រះ ។

● ត្រូវដាក់ជី ក្នុងស្រះ នៅពេលព្រឹក រឺ ពេលថ្ងៃត្រង់ ទើបល្អ

●ករណីទឹកស្រះមានពណ៌បៃតងហើយ កសិករត្រូវឈប់ប្រើប្រាស់ជីតែបើទឹកលែងមានពណ៌បៃតងកសិករត្រូវប្រើជីតាមបរិមាណ ខាងលើឡើងវិញ ។

## ៦~ ការគ្រប់គ្រង

ដើម្បីបំប៉នកូនត្រី ក្នុងស្រះឱ្យបានល្អ អ្នកត្រូវយកចិត្តទុកដាក់ដូចខាងក្រោមនេះ

- ត្រូវរក្សាគុណភាពទឹកស្រះ អោយនៅមានពណ៌បៃតងល្អជានិច្ច ដែលធ្វើឱ្យស្រះរបស់អ្នកសំបូរចំណីធម្មជាតិ សត្វប្លង់តុង និងរុក្ខជាតិប្លង់តុង ជាប្រចាំ
- ត្រូវដាក់ជីឱ្យបានទៀងទាត់ ពិសេសក្នុងករណីទឹកលែងមានពណ៌បៃតង
- ត្រូវផ្តល់ចំណីបន្ថែមអោយបានទៀងទាត់ ដើម្បីឱ្យកូនត្រីឆាប់ធំធាត់ល្អ
- ត្រូវការពារកុំអោយមាន ត្រីស្រែ ពស់ កណ្តុរ និង កង្កែបចូលក្នុងស្រះបំប៉ន ព្រោះវាស៊ីកូនត្រី ។ បើនៅជុំវិញស្រះបំប៉នរបស់អ្នក មានវាលស្រែ និង មាន ទឹក ព័ទ្ធជុំវិញ អ្នកត្រូវយកស្បៃនីឡុងក្រលាល្អិត មកបាំងព័ទ្ធជុំវិញស្រះ ដើម្បី ការពារកុំឱ្យត្រីស្រែលោតចូលស្រះស៊ីកូនត្រី ។
- ត្រូវកំចាត់វាដោយដាក់ បង្កៃ រឺ បិទរន្ធប្រហោង-រូង នៅតាមជើងទេរស្រះ ឬអូសអួន តែមិនត្រូវអូសអួនច្រើនដងពេកទេ ព្រោះនាំ ឱ្យកូនត្រីពុល
- ត្រូវឧស្សាហ៍ត្រួតពិនិត្យមើល សត្វល្អិតចង្រៃ បំផ្លាញកូនត្រីក្នុងស្រះដូចជា សត្វដង្កែរ ទោម ក្តាមទូក កូនព្រៀក ( ក្អាត់) កន្ធង់ហើរ កុំឱ្យមានក្នុងស្រះ ព្រោះវា សំលាប់កូនត្រីអ្នក ។ បើឃើញមានអ្នកត្រូវ ប្រើស៊ុមឈើទំហំប្រហែល ១ម៉ែត្រការ៉េ បណ្តែតលើផ្ទៃទឹកស្រះ ដោយដាក់ប្រេងកាត ឬប្រេងម៉ាស៊ូតពី ៣ ទៅ ៤ស្លាបព្រាបាយ ទៅក្នុងស៊ុមនោះ រួចដាក់អំពូលភ្លើងអាគុយ រឺ ចង្កៀងប្រេងកាតពីលើ នៅពេលយប់ ក្នុងរយៈពេលពី ២ ទៅ ៤ ម៉ោង ។
- អ្នកប្រើវិធីសំលាប់សត្វល្អិតចង្រៃនេះ សំរាប់រយៈពេល ២ អាទិត្យដំបូងតែប៉ុណ្ណោះ គឺនៅក្នុងដំណាក់កាលបំប៉នកូនត្រីម្យ៉ៅ ។







• ករណីកូនត្រីងើបក្បាលច្រើននៅលើផ្ទៃទឹក

នៅពេលព្រឹកព្រលឹមមុនថ្ងៃរះ   គឺ បណ្តាលមកពីទឹកស្រះមិនល្អ ខ្វះខ្យល់អុកស៊ីសែនរលាយក្នុងទឹក   នោះចាំបាច់ ត្រូវ ÷

☞ បាចទឹកស្រះ នៅលើផ្ទៃស្រះ

☞ ប្រសិនបើមានប្រភពទឹកត្រូវបូមទឹកបញ្ចូលស្រះបន្ថែម ដោយដូរទឹកស្រះចាស់មួយចំនួនចេញ ។

☞ ផ្អាកការដាក់ជី និង ចំណី ។

☞ កាត់បន្ថយចំនួនកូនត្រី ដោយរំលែកកូនត្រីមួយចំនួនយកទៅដាក់ស្រះផ្សេងទៀត ។

● បើឃើញទំនប់ភ្លឺស្រះទាប ត្រូវលើកបន្ថែម ដើម្បីការពារកុំអោយទឹកលិចស្រះ ដែលនាំឱ្យត្រីស្រែលោតចូលស៊ីកូនត្រី   និង  ត្រូវដាំស្មៅការពារទឹកស្រះមិនអោយល្អក់ ។

● មិនត្រូវអោយមានម្លប់ដើមឈើ  នៅបាំងជុំវិញស្រះច្រើនពេកទេ   ព្រោះបណ្តាលអោយពន្លឺថ្ងៃ  មិនអាចឆ្លងចូលផ្ទៃទឹកស្រះបាន ។

● ត្រូវឧស្សាហ៍ពិនិត្យមើល  ការលូតលាស់កូនត្រី បើឃើញវាមានទំហំ ពី ២ ទៅ៣ ស.ម  ត្រូវជ្រើសរើស រំលែកដាក់ស្រះបំប៉នកូនត្រីពូជផ្សេងទៀត ដើម្បីអោយវាឆាប់ធំធាត់ល្អ  ។



## ២-  ការបំប៉នកូនត្រីក្នុងហាប៉ា

### ក- បច្ចេកទេសដេរហាប៉ា និង ការរៀបចំហាប៉ាក្នុងស្រះ

ដើម្បីដេរហាប៉ា សំរាប់បំប៉នកូនត្រី កសិករត្រូវ ÷

● យកសាច់អញ្ចងខៀវ ឬ សំណាញ់ជ័រខៀវ ឬ ផ្ទាំងស្បៃនីឡុង  មកដេរអោយមានរាងដូចមុងដេក  ។

● ចំពោះហាប៉ាបំប៉នកូនត្រីម្យ៉ៅ គួរយកផ្ទាំងស្បៃនីឡុងមកដេរ

● ចំពោះហាប៉ាបំប៉នកូនត្រីពូជ គួរយកសំណាញ់ជ័រខៀវមកដេរ

● ហាប៉ាផ្គុំឡើងដោយសំណាញ់ ៣ផ្ទាំង គឺជុំវិញ១ផ្ទាំង  និង បាត២ ផ្ទាំង



● ហាប៉ាត្រូវដេរអោយមានត្រចៀកបួន នៅកាច់ជ្រុងផ្នែកបាត និងផ្នែកខាង លើ និងមានត្រចៀកសំរាប់ស៊កខ្សែចង ចន្លោះពី ១ ទៅ១ ប្រវែងកន្លះម៉ែត្រ នៅផ្នែកខាងលើ ដើម្បីងាយស្រួលចងភ្ជាប់ទៅនឹងបង្គោល ។

● ទំហំហាប៉ា ដែលកសិករនិយមប្រើ គឺបណ្តោយ ៣ម៉ែត្រ ទទឹង ២ម៉ែត្រ និង កំពស់១ម៉ែត្រ ( រឺ ប.៣ម៉ × ទ.២ម៉ × កំ.១ម៉ ) ។



● ដើម្បីតំលើងហាប៉ាក្នុងស្រះ កសិករត្រូវ ÷

☞ មានបង្គោលឈើ រឺ ឫស្សី ចំនួន៤ដើម សំរាប់ចងហាប៉ា

☞ រៀបចំស៊កខ្សែចងក្នុងត្រចៀកហាប៉ាឱ្យហើយស្រេច មុននឹងចុះចង ក្នុងទឹក ។

☞ ដាក់ហាប៉ានៅកាច់ជ្រុងស្រះ រឺ កន្លែងដែលមានទឹករាក់ល្មម ជំរៅប្រហែល ១ម៉ែត្រ ដើម្បីងាយស្រួលត្រួតពិនិត្យ ។

☞ ហាប៉ាត្រូវដាក់ក្នុងស្រះ ដែលមានទឹកពណ៌បៃតង និង ដាក់កន្លែងណាមានពន្លឺថ្ងៃគ្រប់គ្រាន់ ហើយបាតហាប៉ា ត្រូវពន្លិចចូលទៅក្នុងទឹកជំរៅពី ៥០ ទៅ៧០ស.ម ហើយមាត់ខាងលើ នៃហាប៉ាត្រូវឱ្យខ្ពស់ផុតពី ទឹកពី ៥០ ទៅ ៣០ស.ម ដើម្បីកុំអោយកូនត្រីលោតចេញ ។

☞ បាតហាប៉ា ត្រូវដាក់ឱ្យផុតពីបាតស្រះ ដើម្បីចៀសវាងក្តាមកាត់ហាប៉ា ។

☞ បើសិន បាតហាប៉ាអណ្តែត ឬប៉ោងឡើង កសិករត្រូវយកដុំអិដ្ឋ ឬ ដុំថ្ម មួយដុំតូច ដាក់នៅចំកណ្តាលបាតហាប៉ា ។

## ខ. ការចិញ្ចឹមបំប៉នកូនត្រីមេស្រ៊ា និងកូនត្រីពូជ ក្នុងហាប៉ា

### ខ.១-ការលែងកូនត្រី ចូលហាប៉ាបំប៉ន

● ការលែងកូនត្រីចូលហាប៉ាបំប៉ន ដូចគ្នានឹង ការលែងកូនត្រីចូលក្នុងស្រះ ខាងលើដែរ ( មើលក្នុងទំព័រទី ៥-៦ ) ។

● ប៉ុន្តែចំពោះកូនត្រីទីឡាព្យ៉ា នៅពេលឃើញមាន កូនត្រីហែលជាហ្វូង នៅក្នុងស្រះ កសិករអាចដួស ឬដងយកមកបំប៉នក្នុងហាប៉ាកូនត្រីម្សៅ ។

● ហាប៉ាមួយ ដែលមានទំហំ បណ្តោយ ៣ម៉ែត្រ ទទឹង ២ម៉ែត្រ និង កំពស់ ១ម៉ែត្រ អាចដាក់បំប៉នកូនត្រីម្សៅ ៣០០០ ទៅ ៤០០០កូនចំពោះកូនត្រី មានទំហំ ១ស.ម រឺ ៥០០ ក្បាល ក្នុង១ ម៉ែត្រការេ ។



● កូនត្រីពូជ ទីឡាព្យ៉ា ជាមួយ កូនត្រីឆ្ពិន ទំហំពី ១.៥ ទៅ ២ស.ម ហើយ កូនត្រីពូជកាបសាមញ្ញ និង កាបស ទំហំពី ២ ទៅ ៣ស.ម អាចដាក់បំប៉ន បានចំនួន ១៥០០ ទៅ ២០០០កូន រឺ ២៥០ ក្បាល ក្នុង ១ ម៉ែត្រការេ ។

● ចំពោះ កូនត្រីកាបសាមញ្ញ និងកាបស មិនត្រូវដាក់បំប៉នក្នុងហាប៉ា ជាមួយកូន ត្រីទីឡាព្យ៉ា និង កូនត្រីឆ្ពិនទេ ព្រោះធ្វើអោយកូនត្រី កាប - សាមញ្ញ និង កាបស លូតលាស់យឺត ដោយកូនត្រីទីឡាព្យ៉ា និងកូនត្រីឆ្ពិន ដណ្តើមស៊ីចំណីអស់ ។

● ដើម្បីអោយកូនត្រីលូតលាស់បានល្អ និង ងាយស្រួលក្នុងការរាប់កូនត្រី លក់កសិករគួរតែបំប៉នកូនត្រី ដាច់ដោយឡែក១ពីគ្នា តាមប្រភេទនីមួយ១

## ខ.២-ការប្រើចំណីបន្ថែម ក្រោយពេលលែងកូនត្រី

គឺដូចគ្នានឹង ការថែបំប៉នកូនត្រីក្នុងស្រះដែរ ( មើលក្នុងទំព័រទី ៧-៨)

## ខ.៣-ការប្រើជី ក្រោយពេលលែងកូនត្រី

● ក្រៅពីចំណីបន្ថែមខាងលើ ចំណីធម្មជាតិ ( ឬង់គុង) មានសារៈសំខាន់ណាស់ ដល់ការថែបំប៉នកូនត្រី ដោយអ្នកត្រូវជួស ឬង់គុងក្នុងស្រះ មកដាក់អោយកូនត្រីស៊ី ក្នុងហាប៉ា ។

● ទឹកស្រះ ដែលដាក់ហាប៉ា ត្រូវរៀបចំ អោយមានពណ៌បៃតងល្អជានិច្ច ដោយប្រើជី អុយរ៉េ ៣ ខាំ លាយជាមួយជី ដេ អា ប៉េ ១ខាំ រួចកូរជាមួយទឹកឱ្យរលាយអស់ សំរាប់បាច ក្នុងស្រះ ១០០ ម៉ែត្រការេ ។

## គ. ការគ្រប់គ្រង

ដើម្បីថែបំប៉នកូនត្រីក្នុងហាប៉ា ឱ្យបានល្អអ្នកត្រូវយកចិត្តទុកដាក់ដូចខាងក្រោមនេះ

- ចំពោះហាប៉ានីមួយៗ មុននឹងដំឡើងក្នុងទឹក កសិករត្រូវត្រួតពិនិត្យមើលកន្លែង ធ្លុះធ្លាយ និង ដេរឱ្យបានស្អាត ។
- កសិករត្រូវដុសសំអាតហាប៉ា២ដងក្នុងមួយអាទិត្យដោយប្រើដៃ ដុសថ្នមៗ
- មិនត្រូវប្រើច្រាសរឹង ដុសហាប៉ាឡើយ ព្រោះនាំឱ្យរហែកហាប៉ា ។ ការដុស សំអាតនេះ គឺធ្វើអោយប្លង់តុង អាចចូលទៅក្នុងហាប៉ាបានច្រើន ។
- ត្រូវការពារកុំឱ្យ មានពពួកសត្វចង្រៃកាត់ហាប៉ា ដូចជា ក្ដាម កណ្ដុរ ......
- កសិករគួរឧស្សាហ៍ត្រួតពិនិត្យមើលហាប៉ា ក្រែងមានកន្លែងរហែកធ្លុះធ្លាយ
- ត្រូវការពារ កុំអោយមានត្រីកាច ពស់ - កង្កែប -កាចាត ឬកណ្ដុរ ចូលក្នុងហាប៉ា ស៊ីកូនត្រី ។



- អ្នកត្រូវប្ដូរទីតាំងចងហាប៉ា ទៅរកកន្លែងថ្មីជ្រៅល្មម ក្នុងករណីកន្លែងចាស់រាក់ពេក។
- ករណីមានភ្លៀង អ្នកត្រូវប្រុងប្រយ័ត្ន ក្រែងទឹកលិចហាប៉ា នាំអោយកូនត្រីចេញ ។



- ករណីស្រះមានស្មៅ ហើយមានអណ្ដើតត្រា ក្នុងហាប៉ា អ្នកត្រូវរៀវដូសវាចេញ ព្រោះនាំឱ្យកូនត្រីពុល ។
- ត្រូវផ្ដល់ចំណីបន្ថែម ឱ្យកូនត្រីស៊ី ឱ្យបានទៀងទាត់ពេលវេលា
- ត្រូវដាក់ជីបន្ថែមក្នុងស្រះ ករណីទឹកលែងមានពណ៌បៃតង
- ត្រូវឧស្សាហ៍ដួស ប្លង់តុង ពីស្រះដាក់បន្ថែម ឱ្យកូនត្រីស៊ីក្នុងហាប៉ា

# បច្ចេកទេសដឹកជញ្ជូនកូនត្រី

## ១- ការរៀបចំកូនត្រីពូជ មុនពេលចឹកជញ្ជូនសំរាប់លក់

ពេលកូនត្រីមានទំហំពី ៤ ទៅ ៦ស.ម រឺ ២ ទៅ៣ថ្នាំងដៃ អ្នកអាចចាប់លក់ ឱ្យទៅអ្នកចិញ្ចឹមបាន ។




● កូនត្រីពូជមុននឹង ដឹកជញ្ជូនសំរាប់លក់ កសិករ ÷

☞ ត្រូវចាប់កូនត្រីពូជ ដែលត្រូវលក់ចេញពីស្រះ នៅពេលព្រឹក ដាក់ក្នុងហាប៉ា និង មិនត្រូវផ្តល់ចំណីឱ្យវាស៊ីមុន ១ថ្ងៃ មុននឹង ដឹកជញ្ជូន ។

☞ ចំពោះកូនត្រីពូជ ដែលត្រៀមលក់នៅក្នុងហាប៉ា រយៈពេលយូរថ្ងៃ អ្នកអាចឱ្យចំណីវាស៊ីបាន នៅពេលល្ងាច ហើយមិនត្រូវផ្តល់ចំណីឱ្យកូនត្រីស៊ីនៅមុន១ថ្ងៃ ដឹកជញ្ជូនសំរាប់លក់ ។ ព្រោះបើ កូនត្រីស៊ីចំណីឆ្អែត វានឹងបញ្ចេញលាមកយ៉ាងច្រើននៅក្នុងថង់ ដែលបណ្តាល អោយកូនត្រីពុលងាប់ ។

☞ មិនត្រូវលក់កូនត្រី ទៅឱ្យកសិករណា ដែលមិនបានរៀបចំស្រះជាមុន

☞ អ្នកលក់ត្រូវពន្យល់អ្នកមកទិញកូនត្រី អោយយល់ច្បាស់ ពីរបៀបចិញ្ចឹមត្រី ជាមុនសិន ឬ ផ្តល់សៀវភៅបច្ចេកទេស ចិញ្ចឹមត្រីទៅអ្នកទិញ (បើមាន) ទើបលក់កូនត្រីអោយគាត់ ។

☞ អ្នកត្រូវប្រើកញ្ច្រែងការ៉ូ ដើម្បីជ្រើសរើសកូនត្រីពូជឱ្យបានទំហំប៉ុនៗគ្នា សំរាប់លក់ ។



## ២- ការដឹកជញ្ជូនកូនត្រីតូច

ការដឹកជញ្ជូនកូនត្រី មាន២របៀប គឺការដឹកជញ្ជូន ដោយប្រើថង់ និង ការដឹកជញ្ជូន ដោយប្រើធុង ឬ ឆ្នាំង ។

### ក- ការដឹកជញ្ជូនដោយប្រើ ថង់

● ការដឹកជញ្ជូនរបៀបនេះ អាចប្រើសំរាប់ផ្លូវឆ្ងាយ ដោយប្រើខ្យល់ធម្មជាតិ ឬ ខ្យល់អុកស៊ីសែន (បើមាន) ។ អ្នកគួរប្រើ ថង់ប្លាស្ទិច ២ជាន់ ទើបប្រសើរ ។

● ថង់ប្លាស្ទិច ដែលកសិករនិយមប្រើ មានទំហំ បណ្ដោយ ៨០ ស.ម និង ទទឹងមាត់ថង់ ៦០ ស.ម ។

● អ្នកត្រូវដាក់ទឹកស្រះ ១ ភាគ ៣នៃថង់ រួចដាក់កូនត្រីពូជពី ២០០ ទៅ ៣០០ក្បាល ក្នុងមួយថង់ ។ ចំពោះកូនត្រីម្យ៉ៅ អ្នកអាចដាក់ពី ១០០០ទៅ ២០០០កូន សំរាប់លក់ឱ្យកសិករណាដែលយក ទៅបំប៉នទៀតតែប៉ុណ្ណោះ ។

● បន្ទាប់ពីដាក់កូនត្រីរួចហើយ អ្នកត្រូវទាញមាត់ថង់ចំហ ឱ្យខ្យល់ចូល រួចក្របួចមាត់ថង់អោយរហ័ស យកកៅស៊ូកងមកចងមាត់ថង់ឱ្យបានជិតល្អ ។

● កសិករត្រូវត្រៀមកញ្ជេរ ឬ ជាល ឬ ល្អីឬស្សី ហើយទ្រាប់សំបកចេក រួចដាក់ថង់កូនត្រី ទៅក្នុង កញ្ជេរ ឬ ជាល ឬ ល្អីឬស្សីនោះ ដើម្បីការពារកុំឱ្យថង់ធ្លាយ ។

● បើមាន បំពង់ខ្យល់អុកស៊ីសែន ដើម្បីបញ្ចូលខ្យល់ទៅក្នុងថង់ កាន់តែប្រសើរ ។



ដាក់ទឹកមួយភាគបួន នៃកំពស់ថង់



របៀបបញ្ចូលខ្យល់ធម្មជាតិ ក្នុងថង់



របៀបចាប់ក្របួចមាត់ថង់



របៀបចងមាត់ថង់



ថង់កូនត្រីចងរួច




## ២. ការដឹកជញ្ជូនដោយប្រើ ធុង ឬ ឆ្នាំង

ការដឹកជញ្ជូនរបៀបនេះ សំរាប់ដឹកជញ្ជូន ផ្លូវជិត១ ឬ ពីភូមិមួយ ទៅភូមិមួយទៀត តែប៉ុណ្ណោះ ។

- មុនដំបូង ត្រូវដាក់ទឹកស្រះក្នុងធុង ឬ ឆ្នាំង ឱ្យបាន ១ ភាគ ៣នៃធុង ឬ ឆ្នាំងនោះ រួចដាក់កូនត្រី ។
- ដើម្បីកុំអោយកូនត្រីលោតចេញពីឆ្នាំង ឬធុង អ្នកត្រូវប្រើស្បៃ ឬក្រមាគ្រប ចងពីលើ ។
- កសិករអាចរែក ទូល កណ្តៀត ឬជិះកង់ឌុបកូនត្រីនោះ បានយ៉ាងងាយ







# ដំណឹងមានលក់កូនត្រីពូជ យកទៅបំប៉នបន្ថែម

| ខ្ញុំបាទ-នាងខ្ញុំឈ្មោះ | សព្វថ្ងៃមានទីលំនៅ-ក្នុង | | | | មានលក់កូនត្រីតំលៃសមរម្យសំរាប់បំប៉នបន្ថែម- | | | | មានផ្តល់ជូនសៀវភៅ និងពតិមានស្តីពី |
|---|---|---|---|---|---|---|---|---|---|
| | ភូមិ | ឃុំ | ស្រុក | ខេត្ត | ទីឡាព្យ៉ា | កាបសាមញ្ញ | កាបស | ឆ្ពិន | |
| ..............................<br>ជា..............................<br>.............................. | | | | | | | | | បច្ចេកទេសបំប៉នកូនត្រីពូជដោយឥតគិតថ្លៃ |

## ដំណឹងពិសេស

បើ អី ពូ មីង បងប្អូន ជាកសិករដែលមានបទពិសោធន៍ចិញ្ចឹមត្រី មានបំណងចង់ចេះបច្ចេកទេសបំប៉នកូនត្រីពូជ និងចង់បំប៉នទទួលបានជោគជ័យល្អ ដោយខ្លួនឯង សូមមកជូនដំណឹង និងចុះឈ្មោះរបស់អ្នកឱ្យទៅ ឈ្មោះដែលលក់កូនត្រីឱ្យអ្នក ដូចក្នុងតារាងខាងលើ ។ ក្រុមអ្នកបច្ចេកទេសនៃការិយាល័យជលផលខេត្ត....................សហការណ៍ជាមួយនាយកដ្ឋាន ជលផល នឹងចុះទៅបង្រៀនដល់មូលដ្ឋានអ្នក ដោយឥតគិតថ្លៃ ប៉ុន្តែ គ្មានការឧបត្ថម្ភសំភារះអ្វី ក្រៅពីបច្ចេកទេសនេះទេ ។





រៀបរៀងដោយ ការិយាល័យវារីវប្បកម្ម នាយកដ្ឋានជលផល ឧបត្ថម្ភដោយកម្មវិធីវារីវប្បកម្ម AIT នៅកម្ពុជា . អាស័យដ្ឋាន ឡូតិ៍លេខ ១៨៦ មហាវិថីព្រះនរោត្តម ភ្នំពេញ . ទូរស័ព្ទ-ទូរសារ ០២៣ ២១០ ៥៦៥

| | |
|---|---|
| រៀបរៀងដោយ | : ការិយាល័យវារីវប្បកម្ម នាយកដ្ឋានជលផល ភ្នំពេញ |
| ឧបត្ថម្ភដោយ | : កម្មវិធីវារីវប្បកម្មរបស់ AIT នៅកម្ពុជា |
| ទំហំ | : ២១ ស.ម x ៣០ ស.ម |
| បោះពុម្ពលើកទី១ | : ១០០០ ក្បាល |

រាជធានីភ្នំពេញ ថ្ងៃទី១០ ខែឧសភា ឆ្នាំ២០០០


ការិយាល័យវារីវប្បកម្ម នាយកដ្ឋានជលផល ឡូត៍លេខ ១៨៦ មហាវិថីនរោត្តម ភ្នំពេញ ប្រអប់សំបុត្រលេខ ៨៣៥ ទូរស័ព្ទ-ទូរសារ : (៨៥៥-២៣) ២១០ ៥៦៥ / **E-mail: smallfish@bigpond,com.kh**